**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

លេខ ១១៨៤/១៨ ស.ជ.ណ

ថ្ងៃអង្គារ ១១រោច ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

កំពង់ធំ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំព្រឹត្តិការណ៍សង្ក្រាន្តថ្មីសំបូរព្រៃគុក ឆ្នាំ២០១៨

រដ្ឋបាលខេត្តកំពង់ធំ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណៈជន បងប្អូនប្រជាពលរដ្ឋ ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ឲ្យបានជ្រាបថា ដើម្បីអបអរសាទរពិធីចូលឆ្នាំថ្មី ឆ្នាំច សំរឹទ្ធិស័ក ពុទ្ធសករាជ ២៥៦២ ដែលនឹងឈានចូលមកដល់នាពេលដ៏ខ្លីខាងមុខនេះ រដ្ឋបាលខេត្តកំពង់ធំ នឹងរៀបចំព្រឹត្តិការណ៍ " សង្ក្រាន្តថ្មីសំបូរព្រៃគុក ឆ្នាំ២០១៨ " លើកទី៤ នៅតំបន់ប្រាសាទសំបូរព្រៃគុក អតីតរាជធានី ឥសានបុរៈដ៏ចំណាស់ និងជាសម្បត្តិបេតិកភណ្ឌពិភពលោក រយៈពេលបីថ្ងៃ គឺ ចាប់ពីថ្ងៃ ១៤រោច ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ដល់ថ្ងៃ២កើត ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងទី១៤ ដល់ថ្ងៃទី១៦ ខែ មេសា ឆ្នាំ ២០១៨ ខាងមុខនេះ ។

ព្រឹត្តិការណ៍សង្ក្រាន្តថ្មីសំបូរព្រៃគុកឆ្នាំ២០១៨ ដែលគ្រោងរៀបចំនេះ មានកម្មវិធី ជាអាទិ៍ ពិធីទទួលទេវតាឆ្នាំថ្មី ពិធីស្រង់ព្រះ ល្បែងប្រជាប្រិយ របាំប្រជាប្រិយ របាំប្រពៃណី ដែលជាទំនៀមទម្លាប់ ប្រពៃណីដ៏ល្អផូរផង់តាំងពីបុរាណកាល ព្រមទាំងមានពិធីមួយចំនួនទៀតដូចជា ពិធីហែក្បួនយុវជន ពិព័រណ៍ភូមិគួយនិម្មិត ពិព័រណ៍សមិទ្ធផលនានារបស់បណ្តាមន្ទីរ អង្គភាពក្នុងខេត្ត ផ្ទាំងទស្សនីយភាពសិល្បៈ ការប្រគុំតន្ត្រី និងរាំកំសាន្ត ការប្រណាំងរទេះគោ ។ល។និង។ល។ ដោយឡែក ពេលរាត្រី នៅឯទីរួមខេត្តកំពង់ធំ ក៏មានការប្រគុំតន្ត្រី និងការបាញ់កាំជ្រួចជូនទស្សនាកំសាន្តផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន បងប្អូនប្រជាពលរដ្ឋ ភ្ញៀវជាតិ និងអន្តរជាតិ ចូលរួមកំសាន្តសប្បាយរីករាយឲ្យបានច្រើនកុះករ។

**អភិបាល**

**សុខ~លូ**

**<u>ចម្លងជូន</u>** ÷

-ក្រុមប្រឹក្សាខេត្ត

" ដើម្បីជូនជ្រាប"

-មន្ទីរ អង្គភាពក្នុងខេត្ត

-រដ្ឋបាលក្រុង ស្រុក

" ដើម្បីផ្សព្វផ្សាយ "

-ឯកសារ-កាលប្បវត្តិ